**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)
លេខ ០៣០/២២ គ.វ.ក-១៩

ថ្ងៃ ៩ ៨កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០២២

# សេចក្តីជូនព័ត៌មានបន្ថែម

## ស្តីពី

## ការបន្ថែមទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ សម្រាប់ក្រុមគោលដៅជម្រើសនៅរាជធានីភ្នំពេញ

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) សូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា បន្ទាប់ពីការចេញសេចក្តីជូនព័ត៌មានលេខ ០១៥/២២ គ.វ.ក-១៩ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២២ ស្តីពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ដោយប្រើវ៉ាក់សាំង Pfizer សម្រាប់ក្រុមគោលដៅជម្រើសនៅរាជធានីភ្នំពេញ **គ.វ.ក-១៩** សូមជូនព័ត៌មានបន្ថែម ស្តីពីការបន្ថែមទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ជូនដល់មន្ត្រីរាជការចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាជិក សមាជិកា នៃសភាពាណិជ្ជកម្ម ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញរួច ហើយមានគម្លាតចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ដូចខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង-អង្គភាព | កាលបរិច្ឆេទ | ពេលវេលា | ទីតាំងចាក់វ៉ាក់សាំង |
|---|---|---|---|---|
| ០១ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០៧ - ០៩ កុម្ភៈ ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ | មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| ០២ | សភាពាណិជ្ជកម្ម | ១០ - ១១ កុម្ភៈ ២០២២ | | |

អាស្រ័យដូចបានជម្រាបជូនខាងលើ **គ.វ.ក-១៩** សូមអំពាវនាវដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី នៃក្រុមគោលដៅខាងលើទាំងអស់មេត្តាជ្រាប និងអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ ឱ្យបានគ្រប់គ្នា។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទខាងក្រោម៖

ក-ក្រុមការងារទំនាក់ទំនងសាធារណៈ /លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៩៨៩ ០៨៥ | ០៨៩ ៩៨០ ៦៦៦ | ០១០ ២៣៣ ៥៨៨ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា៖

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៦៨ ៩០៦ ៦៦៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងវ៉ាក់សាំង៖

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)**

វេជ្ជ. ឱ្យ វណ្ណឌីន



Scanned with SwiftScan